ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
៣៣៣

ក្រសួងធនធានទឹក និងឧតុនិយម

លេខ ២៤៣ សជណ ធទឧ

# សេចក្តីជូនដំណឹង ស្តីពី
# ស្ថានភាពអាកាសធាតុ និងស្ថានភាពទឹកជំនន់ទន្លេមេគង្គ

បន្ទាប់ពីបានធ្វើការសង្កេត ពិនិត្យ តាមដាន លើស្ថានភាពទឹកជំនន់ និងអាកាសធាតុ រួចមក ក្រសួងធនធានទឹក និងឧតុនិយម សូមជម្រាបជូនដំណឹងដល់ក្រសួង-ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដី សាធារណជន ពិសេសបងប្អូនប្រជាកសិករ ឱ្យបានជ្រាបដូចខាងក្រោម :

១- ស្ថានភាពអាកាសធាតុ : បើទោះបីជារដូវវស្សាឆ្នាំ ២០១១ នេះ នឹងអូសបន្លាយរហូតដល់ដើមសប្តាហ៍ទី ២ នៃខែវិច្ឆិកា ក៏ដោយ តែរបាយណ៍ទឹកភ្លៀងដែលនឹងត្រូវធ្លាក់ចុះ មិនមានបរិមាណច្រើនដូចពេលកន្លងមកនោះទេ ។

២- ស្ថានភាពទឹកជំនន់ទន្លេមេគង្គ ទន្លេសាប និងទន្លេបាសាក់ នឹងបន្តស្រកចុះជាបន្តបន្ទាប់ ។

យោងលើស្ថានភាពអាកាសធាតុ និងស្ថានភាពទឹកជំនន់ ខាងលើ ក្រសួងធនធានទឹក និងឧតុនិយម សូមជម្រាបជូនដំណឹងដល់ក្រសួងស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដីគ្រប់រាជធានី-ខេត្ត ពិសេសបងប្អូនប្រជាកសិករទាំងអស់ **ត្រូវមានវិធានការរក្សាទឹកទុក** សម្រាប់បម្រើឱ្យការងារបង្កបង្កើនផល ពិសេសការបង្កបង្កើនផលស្រូវរដូវប្រាំង នាពេលខាងមុខនេះ ។

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ ២០១១

រដ្ឋមន្ត្រី

លឹម គានហោ

អគារលេខ ៤៧ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ ទូរស័ព្ទ / ទូរសារលេខ (៨៥៥ ២៣.៧២៥ ៩៨៩ / (៨៥៥ ២៣.៤២៦ ៣៤៥
# 47 Preah Norodom B V D. Phnom Penh, Fax/Phone: ( 855) 23.725 989 / ( 855 ) 23.426 345 E-mail : mowram@cambodia.gov.kh